# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ៨

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៣

គ.ស. ១៩៤១

ល : 01

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ៨

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៣

គ. ស. ១៩៤០

# បញ្ជីរឿង


ទំព័រ

១ — និយាយអំពីបាតសមុទ្រ . . . . . . . . . . . . . . . . . . . . . ៣

២ — និយាយអំពីសេចក្ដីសំខាន់ ៗ ក្នុងសៀវភៅមួយរបស់ប្រទេសជប៉ុន . . . . . ៨

៣ — ចំពោះប្រទេសជាក់ងសែស . . . . . . . . . . . . . . . . . . ១១

៤ — ច្បាប់សុភាសិត របស់អ្នកឧកញ៉ាវង្សាសារពេជ្ញ (នង) (តមក) . . . . . . . ១៣

៥ — អំពីព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូស៊ីន របស់លោកឌុកទ័រអងគ្រើមិកូត (តនឹងចប់) . . . . . . . . . . . . . . . . . . . . . . ១៧

៦ — ពង្សាវតារប្រទេសក្រិក សេចក្ដីប្រែនឹងរៀបរៀងចេញពីគោលជាក់ផ្សេង ៗ ក្នុងពង្សាវតារលោក (តមក) . . . . . . . . . . . . . . . . . . ២៤


## រូបក្រៅរឿង


ក្រុងហ្លួងព្រះបាង — ដំរីព្រះរាជទ្រព្យនៅឱកាសចូលឆ្នាំថ្មីប្រទេសលាវ . . . . ១

# TABLE DES MATIÈRES


Pages.

1° Le fond de la mer ........................................ 3

2° Extrait du livre intitulé "Japon" ........................................ 8

3° Pour la France ........................................ 11

4° Chbab Subhāsit (Poème Khmèr) par Oknhā Vongsāsāra Péch (Nong) suite ........................................ 13

5° Le Bouddhisme en Indochine par le Docteur André Migot (suite et fin) ........................................ 17

6° Histoire de la Grèce, extraits de divers documents de l'Histoire Universelle (suite) ........................................ 24


HORS TEXTE:


Luong-Prabang — L'éléphant du Roi ........................................ 1



ក្រុងហ្លួងព្រះបាង — ដំរីព្រះរាជទ្រព្យនៅឱកាសចូលឆ្នាំថ្មីប្រទេសលាវ ។

# និយាយពីបាតសមុទ្រ

ដោយអំណាចវិទ្យាសាស្ត្រទំនើបថ្មីនៃពួកអ្នកប្រាជ្ញដែលខំសិក្សាឲ្យដឹងរឿងរ៉ាវក្នុងបាតមហាសមុទ្រ ហើយនាំមកពន្យល់យើងឲ្យបានដឹងសេចក្ដីដោយច្បាស់លាស់ដូចជារឿងរ៉ាវដែលមាននៅលើផែនដីដែរ ។ គេបានថតយករូបផ្សេងៗដែលមាននៅក្នុងបាតសមុទ្រហើយធ្វើជាខ្សែកុនឡើង ទើបយើងបានដឹងនឹងឃើញរឿងរ៉ាវអស់នោះដែលមាននៅក្នុងបាតសមុទ្រ ។ មានសៀវភៅ ១ ល្អណាស់ បាននិយាយពន្យល់ពីកិច្ចការក្នុងបាតសមុទ្រដោយច្បាស់លាស់ ។ លោកអ្នកតែងរឿងនេះគឺលោកវិល្លាមស៊ិន (Williamsan) ដែលជាអ្នករៀបចំធ្វើប្រដាប់ថត ១ ជាដំបូងសម្រាប់យកទៅថតនៅបាតសមុទ្រ ។ លោកបានធ្វើប្រដាប់ ១ យ៉ាងវិសេស សុទ្ធតែកញ្ចក់ (យ៉ាងក្រាស់ដូចជាកូនបន្ទប់១) សម្រាប់ចុះទៅឲ្យដល់បាតសមុទ្រ ហើយមានបំពង់ខ្សែខ្យល់១ទន់សម្រាប់បង្អូតប្រដាប់នោះចុះទៅ ចុងបំពង់ចង់ភ្ជាប់នឹងទូក បំពង់នេះហើយសម្រាប់បញ្ចេញបញ្ចូលខ្យល់អាកាស ឲ្យពួកអ្នកធ្វើការនៅបាតសមុទ្រនោះ ដោយសារប្រដាប់ដ៏វិសេសសម្រាប់ឲ្យមើលអ្វីៗបាន នឹងគ្រឿងដុះបញ្ចាំងភ្លើងដោយឡែកទៀតនោះ លោកវិល្លាមស័ននឹងពួកអ្នកធ្វើការរួបរួមជាមួយនឹងលោក អាចថតយករូបផ្សេងៗបានជាច្រើន យកមកធ្វើជាខ្សែកុន

និយាយពីកិច្ចការនៅបាតសមុទ្រ ក្នុងតំបន់ដែលមានភ្នំក្រំថ្មអស់នោះ. លោកនិយាយពីគំនរខ្សាច់មានលក្ខណៈជាផ្កាថ្មនោះមានច្រើនណាស់ពាសពេញក្នុងបាតសមុទ្រ ។ មានខ្យល់ព្យុះកើតឡើងដែលបានឃើញក្នុងបាតសមុទ្រនោះ ក្នុងខណៈដែលមានរលកធំៗកើតឡើងលើផ្ទៃទឹក ប៉ុន្តែនៅបាតសមុទ្រនោះមានតែរលកតូចៗទៅវិញ ។ កាលណាមានភ្លៀងធ្លាក់នៅលើខ្នងទឹក គេនឹកស្មានថាដូចជាមានគ្រាប់សំណទម្លុះទឹកចុះទៅ២-៣ សង់ទីម៉ែត្រ ។ កាលណាមានខ្សែទឹករលកមួយរញ្ជួយនៅបាតសមុទ្រហើយមានរលកតូចបែកសាយភាយទៅ ហើយគេបានឃើញត្រីធ្លាមហែលទៅយ៉ាងលឿន មានត្រីធ្លាមខ្លះដេកសម្រាកលើគំនរខ្សាច់ ត្របាក់លេបទឹកហាមាត់ធំៗ ។ មានម្តងទៀតនោះ គេបានចុះទៅក្នុងព្រៃផ្កាថ្មគេបានឃើញត្រីសេក ១ នៅខាងមុខបន្ទប់កញ្ចក់ ខ្លួនវាមានសម្បុរខៀវចាស់ ចំពុះវាដូចជាចំពុះសេក តែមានលក្ខណៈរឹងមុឹងដូចជាថ្ម ហើយវាស្ទុះចឹកបន្ទប់កញ្ចក់ មានស្នាមក្រឡៅដូចជាចោះ ។ អស់ទាំងមើមឈើដែលមាននៅបាតសមុទ្រនោះស្រស់ល្អទឹងមានពណ៌ផ្សេងៗគឺ ក្រហម, ខៀវ, លឿង, ប្រផេះ ។ លោកនិយាយពន្យល់ពីវិធីដែលត្រីធ្លាមត្របាក់ស៊ីអាហារចំណីរបស់វា មានត្រីធ្លាម ១ ឬ ២ វាហាមាត់ត្របាក់បន្ទប់កញ្ចក់ ហើយវាហែលមកក្បែរៗឥតខ្លាច ទុកជាគ្រឿងប្រដាប់នេះ

មានខ្នាតធំហើយធ្ងន់យ៉ាងណាក៏ដោយ ក៏នៅតែកក្រើករញ្ជួយ មានថ្គាម យ៉ាងខ្នាតធំ ១ នោះមកខាំកកេរដោយធ្មេញដ៏មុត ត្រង់ដែកទឹងកញ្ចក់នៃគ្រឿងប្រដាប់សម្រាប់ធ្វើការនោះ ៗ វិធីស៊ីអាហារនៃសត្វថ្គាមអស់នេះ វាមិនទំពាស៊ីដូចសត្វឯទៀតៗទេ វាច្រើនខាំកាត់ជាកំណាត់ៗ ទឹងខាំកើបកន្ត្រាក់ ៗ

នៅស្រុកឈិកាកូ ប្រទេសអាមេរិក លោកអូទ័រព្រមទាំងអ្នកធ្វើការជាមួយនឹងលោក និយាយពីកិច្ចការដែលបានធ្វើនៅបាតសមុទ្រ ក្នុងខណៈដែលបានចុះទៅមើលក្បែរកោះ ១ នោះ នៅកណ្ដាលទីដែលមានសួនច្បារជាតិទឹក ត្រង់កន្លែងដែលចូលទៅក្នុងព្រៃ ១ នៅក្រោមទឹក ៗ លោកអូទ័របានពិនិត្យមើលនិងថតយកអស់ទាំងកិច្ចការសព្វសារពើដែលមាននៅក្នុងបាតសមុទ្រនោះ ដើម្បីយកមកសំដែងនៅស្រុកឈិកាកូ ៗ

នៅតំបន់នេះមានត្រីជាច្រើន សឹងមានពណ៌ផ្សេងៗគ្នា សម្ងំដេកនៅក្នុងគុហាងងឹត ដែលបានឃើញជាដំបូងនោះ គឺបានឃើញត្រី ១ ពួកដូចជានាំគ្នាសម្ងំដេក តែតាមពិតនោះ មិនដេកទេ វាភ្ញាក់ព្រាកជានិច្ចកាលបើមានគ្រោះថ្នាក់មក វាក៏ហែលរត់ពីទីដេកនោះទៅ ៗ ការឃើញជាគំរប់ពីរ ស្រាប់តែឃើញពួកត្រីអស់នោះរត់បាត់អស់ទៅ ព្រោះមានត្រីមួយពួកទៀតលោស្រកីហាមាត់ចង្គ្រងហែលសំដៅមក ធ្វើឲ្យទឹករញ្ជួយ

ជាខ្ទាំងចូលហួសទៅដល់កណ្តាលកន្លែងដែលជាសជាយផ្កាថ្ម ៗ ក្នុង
មួយស្របក់នោះ ស្រាប់តែត្រីដែលមានពណ៌ផ្សេងៗអស់នោះ ត្រឡប់
មកកន្លែងវាវិញសម្ងំនៅយ៉ាងស្ងាត់ស្ងៀម ឥតគិតភ័យអ្វី ៗ

មានសត្វសមុទ្រ ១ យ៉ាងទៀតហៅថា ប៉ូលីប (Polype) ជាសត្វ
មានខ្លួនតូចថ្លាយ៉ាងចំឡែកដូចជាកែវ ទុកជាវាមានខ្លួនមិនធំជាងក្បាល
ម្ជុលខ្ទាស់ក៏ដោយ ខ្លួនវាក៏នៅតែមានធ្មេញច្រើនស្អេកស្កស់ ៗ កាល
ណាវាទៅស្វែងរកអាហារក្នុងទឹកសមុទ្រនោះ សត្វប៉ូលីបនេះវាបញ្ចេញ
ប្រមោយ ២ គូដែលនៅជុំវិញខ្លួនវា ទុកដូចជាលំពែងដែលលាបថ្នាំបំពុល
វាអាចចាក់ឬពួយទៅត្រូវសត្វជាអាហាររបស់វា ទុកជាសត្វនោះនៅឃ្លាត
ឆ្ងាយពីខ្លួនវាក៏ដោយ ៗ សត្វនោះវាស៊ីតែសត្វរស់ៗ ត្រាតែពេញក្រពះវា
តាមចំណង់របស់វា ៗ

បន្ទប់កញ្ចក់នៅក្រោមសមុទ្រ ជាកន្លែងដែលអ្នកទំរធ្វើការនោះជាទី
ស្រឡះទូលាយគ្រាន់បើដែរ ហើយមានកង្ហារបញ្ចូលខ្យល់អាកាសឲ្យបាន
មានដង្ហើមដកបានស្រួល នឹងធ្វើដំណើរក្នុងទឹកបានស្រួល ៗ លោកបាន
ទៅប្រទះឃើញវត្ថុផ្សេងៗ នឹងកប៉ាល់ដែលលិចបាត់ទៅជាយូរឆ្នាំ ហើយ
នោះ ក្លាយទៅជាគំនរដែកនឹងឈើ១ដុំនៅក្នុងបាតសមុទ្រ មានថ្មកំបោរ
នឹងផ្កាថ្មដុះច្រូងច្រាងឡើង ជាទីជ្រកកោននៃសត្វត្រីជាចំនួនច្រើនណាន

នៅក្បែរៗសំបកកប៉ាល់នោះជាទីប្រជុំនៅនៃសត្វត្រី នាំឲ្យមានជារឿងចំឡែកឡើង គឺមានត្រីយ៉ាងច្រើនសំបើមនៅទីនោះ កាលណាមានសត្វឆ្មាមួយបើកភ្នែកសំឡឹងដាក់ហ្វូងត្រីមួយក្រុម ដែលវាត្រូវការធ្វើជាចំណីអាហាររបស់វា ដោយអំណាចឫទ្ធិអំណាចភ្នែកវានោះ ធ្វើឲ្យត្រី ១ ខ្លួត ចេញចាកហ្វូងត្រីនោះមកហើយមានខ្លួនញ័ររំប្រប់ ។ ក្នុងខណៈដែលត្រីធំៗហាមាត់ឡើងលេបត្រីតូចៗនោះ វាតែងតែហាមាត់ត្របាក់លេបទាល់តែឆ្អែតបាត់ឃ្លាន ។

# សេចក្ដីសំខាន់ៗក្នុងសៀវភៅមួយដែលនិយាយពីជប៉ុន

ព្រះរាជបណ្ណាល័យទើបនឹងបានទទួលសៀវភៅមួយ ដែលជនជាតិជប៉ុនម្នាក់បានតែងជាភាសាបារាំងសែស ហៅថា “ជប៉ុន Japon” ។

យើងបានមើលសេចក្ដីត្រង់ដែលនិយាយពីប្រយោជន៍ព្រះត្រៃបិដកដែលបានចម្លងមកពីស្រុកឥណ្ឌា ហើយផ្សាយមកដល់ស្រុកចិន បានបោះពុម្ពផ្សាយជាភាសាចិន ប៉ុន្តែមកដល់សម័យសព្វថ្ងៃនេះ នៅស្រុកឥណ្ឌានឹងស្រុកចិនព្រះត្រៃបិដកមហាយានមានមិនបរិបូណ៌សព្វគ្រប់ទេ ៗ ប៉ុន្តែនៅស្រុកជប៉ុនសព្វថ្ងៃនេះ គេបានរក្សាព្រះត្រៃបិដកមានចំនួន ៣០ ឈុតចប់សព្វគ្រប់ បើមានអ្នកត្រូវការចង់រៀនសូត្រគម្ពីរព្រះពុទ្ធសាសនា (ប៉ែកខាងមហាយាន) គោងតែទៅរៀននៅប្រទេសជប៉ុន ៗ

តាំងពីកណ្ដាលឆ្នាំពុទ្ធសករាជ ១០៥០ មក ព្រះពុទ្ធសាសនាជួយការពារជីវិតសត្វទាំងឡាយក្នុងប្រទេសជាច្រើន ដោយប្រជាជនជ្រួតជ្រាបស្រឡាញ់ពុទ្ធសាសនាទួទៅ ព្រោះហេតុនេះហើយបានជាជនជាតិជប៉ុនមិនប្រើគ្រឿងស្លៀកពាក់ដែលធ្វើពីរោមសត្វដូចជាសំពត់រោមចៀម (ជាដើម) ប៉ុន្តែគេប្រើសូត្រ មានវិធីចិញ្ចឹមនាងធ្វើសូត្រត្បាញសំពត់តាំងអំពីបុរាណកាលយូរមកហើយ គេតែងធ្វើប្រើក្នុងប្រទេសរបស់គេ ៗ តាំងពីពុទ្ធសករាជ ២.០០០ ស្រុកចិនបាននាំកប្បាសមកលក់នៅស្រុកជប៉ុនជា

ច្រើន ហើយការធ្វើជំនួញលក់សំពត់អំបោះក៏មានសេចក្តីចំរើនកើនឡើងជាលំដាប់ ៗ ព្រះពុទ្ធសាសនារបស់ជប៉ុនបានធ្វើឲ្យកើតសេចក្តីចំរើន ដូចជាព្រះពុទ្ធរូបទឹងគ្រឿងដូងគាំង មានដួងមួយនោះមានខ្នាតធំសំបើមអស្ចារ្យ ធ្វើប្រជាជនឲ្យមានសីលធម៌ល្អ មានចិត្តស្រឡាញ់វង្សត្រកូល មានចិត្តកតញ្ញូ សឹងសំដែងឲ្យឃើញប្រាកដច្បាស់ក្នុងពេលដែលមានជី-វិតរស់នៅនិងស្លាប់ទៅនៃចៅហ្វាយនាយធំៗ ។ ព្រះពុទ្ធសាសនាបានប្រដៅឲ្យស្គាល់សេចក្តីទុក្ខ៤ប្រការប្រចាំជីវិតមនុស្សគ្រប់រូប គឺជាតិទុក្ខ១ ជរាទុក្ខ១ ព្យាធិទុក្ខ១ និងមរណទុក្ខ ១ ។ ការធ្វើឲ្យមានជ័យជំនះសេចក្តីទុក្ខទាំង៤ ប្រការនេះ លុះតែខំព្យាយាមប្រឹងប្រែងឲ្យបានដល់វិមុត្តិ ដែលជាចុងផ្លូវនៃលទ្ធិពុទ្ធសាសនានេះ គឺជាត្រូវខំព្យាយាមលះបង់សេចក្តីទុក្ខទាំងអស់ក្នុងលោកនេះ ក្នុងការរួបរួមសមាគមជាមួយគ្នា ក្នុងការលះបង់ជីវិតរបស់ខ្លួន ដោយទំនងនេះហើយបានជាធ្វើឲ្យយើងបាត់ខ្លាចសេចក្តីស្លាប់ដែលជាធម្មជាតិមួយដែលមនុស្សគ្រប់ៗស្រុកតែងតែកោតខ្លាច ។ ទំនងនេះហើយជាគ្រឿងបង្ហាត់ចិត្តមនុស្សឲ្យហ៊ានទទឹងសេចក្តីស្លាប់ ក្នុងនាមរបស់គ្រួសារនិងរបស់ប្រទេស ។

អានុភាពរបស់ពុទ្ធសាសនានេះបានចូលជ្រៀតជ្រែកក្នុងចិត្តគំនិតរបស់ជនជាតិជប៉ុនស្ទើរតែគ្រប់ថ្នាក់គ្រប់ជាន់ទាំងអស់ ៗ

ឯវិជ្ជាពេទ្យបែបអឺរុបនោះ ពួកជប៉ុនបានរៀនសូត្រអំពីពួកហុល្លង់ដេស៍ ហើយសៀវភៅជាក្បួនច្បាប់ខាងធ្វើថ្នាំផ្សំថ្នាំក៏បានប្រែពីភាសាហុល្លង់-ដេស៍មកជាភាសាជប៉ុនដែរ តាំងពីពុទ្ធសករាជ ២.៣១៧ ។ លុះដល់មកពុទ្ធសករាជ ២.៣៩២ ទើបពួកជប៉ុនចាប់ផ្តើមរៀនវិជ្ជាពេទ្យជាភាសាអង់-គ្លេស ហើយគេផ្តើមមើលជម្ងឺក្នុងឡើងជាដំបូងតាមបែបអឺរុប ។

លុះមកដល់ពុទ្ធសករាជ ២.៣៦៦ ទើបមានគ្រូពេទ្យជាតិអាល្លឺម៉ង់ទៅតាំងកន្លែងនៅស្រុកជប៉ុន ហើយបានបើកសាលាបង្រៀនវិជ្ជាពេទ្យមួយនឹងបង្រៀនវិជ្ជាផ្សំថ្នាំ ។

លុះដល់មកពុទ្ធសករាជ ២.៣៩៧ ទើបគេបង្កើតសមាគមដោះអុតឡើងក្នុងប្រទេសជប៉ុន ។

# សម្រាប់នគរបារាំងសែស

ជាតិយួនម្នាក់បានទាំងជា "អាសង់តិចណាំច" ក្នុងក្រសួងសាធារណការ ដែលឈប់ធ្វើការដោយដល់កំណត់ឆ្នាំ ហើយដែលរកការបានគេណ្ហាឲ្យធ្វើការវិញ ចង់ចូលកុសលក្នុងការជំនួយជាតិទៅវិញទៅមក បានសុខចិត្តជូនប្រាក់ខែមួយខែជាជំនួយ ។

អ្នកកាន់ការខាងលើនេះ បានផ្ញើប្រាក់នេះទៅលោក "អ្នកនាយក [illegible] ក្នុងក្រសួងសាធារណការ [illegible] ទៀត ទៅ"មន្ទីរក្រសួងជំនួយបារាំងសែស-ឥណ្ឌូចិន ឲ្យបានដល់ទៅអ្នកដែលបានទទួលកម្មអកុសលក្នុងការចម្បាំង" ។

លោកអាសង់តិចណាំចជាតិយួននេះបានសរសេរសំបុត្ររៀបពាក្យយ៉ាងល្អមួយច្បាប់ជូនជាប់ជាមួយនឹងប្រាក់នោះ អ្នកចាំមើលជាការបន្ទាល់សំគាល់ថាដែលលោក (បារី) ហៅថាការធ្វើឲ្យគេស្រឡាញ់ស្ម័គ្រចិត្ត ។

"ដោយខ្ញុំគិតទៅអ្នកមានគុណ ជួយទំនុកបំរុងខ្ញុំទាំងអស់ដែលមានគ្រូបង្រៀនខ្ញុំពីដើមជាច្រើននាក់ ទឹងនាយបៅហ្វាយខ្ញុំដែលឈប់ធ្វើការដោយដល់កំណត់ឆ្នាំសព្វថ្ងៃ នៅនគរបារាំងសែសខ្ញុំខាននឹកគិតដល់ការខូចខាតវិនាសអន្តរាយច្រើនណាស់មិនបាន ការចង្រៃវេទនាដែលនគរបារាំងសែសទើបនឹងទទួល" ។

"ដូច្នេះ កាលណាខ្ញុំនឹកគិតទៅអ្នករៀនចំណេះវិជ្ជាដែលគ្មានភ័ព្វសំណាង ខ្ញុំនៅធ្វើព្រងើយមិនកើត ដោយឃើញសេចក្ដីទុក្ខលំបាកវេទនារបស់អ្នកទាំងអស់នោះ នៅខណៈដែលយើងកំពុងលេងសប្បាយរីករាយនៅប្រទេសឥណ្ឌូស៊ីន នូវសេចក្ដីសុខក្សេមក្សាន្ត ដែលជនទាំងឡាយប្រាថ្នាយ៉ាងខ្លាំង កើតឡើងដោយសារគំនិតប្រាជ្ញាកជការគ្រប់គ្រងផែនដី ។

"ពីដើមខ្ញុំបានរៀនពីគ្រូបង្រៀនច្រើននាក់ ហើយបានទទួលប្រាក់ជំនួយឲ្យរៀនពីកជការទៀត ឥឡូវនេះត្រូវខ្ញុំយកប្រាក់បូលជួយក្នុងការកសាងជួសជុលបង្កើតថ្មី ហើយនឹងជួយបងប្អូនទាំងឡាយដែលនៅស្រុកជាមួយខ្ញុំ នៅនគរបាកំងសែសដែលគ្មានសំណាងដូចអ្នករៀមច្បងទៅរៀនជាន់មុន" ។

"របស់ដែលខ្ញុំជូនលោកអ្នកនាយកត្រួតត្រាលើការគ្រប់ជំពូក គឺជាប្រាក់ខែតែមួយខែទេ របស់អ្នកកជការឈប់ធ្វើការដោយដល់កំណត់ឆ្នាំដែលកជការកេណ្ឌឲ្យធ្វើការ (គឺប្រាក់ ១៣៥៛,០០ ក្នុងចំនួនទឹកប្រាក់នេះ ១០០៛,០០ សម្រាប់ជួយនគរបាកំងសែស ក្នុងការជួសជុលបង្កើតថ្មី ហើយ ៣៥៛,០០សម្រាប់ជួយពួកប្រទេសឥណ្ឌូស៊ីនជាអ្នករៀនគ្រជុតដៃដើងនេះគឺខ្សាច់មួយគ្រាប់បោលទៅក្នុងសមុទ្រប៉ាស៊ីហ្វិក ផ្ទុះទៅប្រាក់ពាន់រយកោដិ តែជាសេចក្ដីសំដែងឲ្យឃើញសេចក្ដីដឹងគុណ សេចក្ដីសប្បុរសអាណិតអាសូរ ។ គឺមនុស្សចិត្តស្មោះត្រង់ម្នាក់ឲ្យប្រាក់នេះ" ។

នេះ

# ច្បាប់សុភាសិត

ប្រសើរពេកពិត ប្រែពីគាថា
បន្ទូលព្រះពុទ្ធ បំបាត់ទោសា
ឲ្យអស់ទាំងមហា- ជនផងត្រងត្រាប់ ។

និព្វានប្បច្ចយោ ហោតុ មេ ។

របស់

ឧកញ៉ាវង្សាសារពេជ្រ នង ចាងហ្វាងក្រុមរាជបណ្ឌិត

ក្នុងរាជ្យព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី

(ព្រះអង្គដួង) ។

(តខក)

ឈើសោតបើពុំមាន	សន្ទឹកឡើយសឹងស្ងួតសោះ ។
មេគោសោតឥតក្សីរ	ក្សិណនេះសទីនៃទឹកដោះ
វាក្យពុំពីរោះ	សឹងស្ងួតសោះពុំសើផ្លា ។

៤៦ — យោធម្មសីលា	ជិតឈានគោសោ
វិជ្ជាវិធិតោ	ឆបកេបតាបិ ។
សុនារត្តា	បរនារវជ្ជិ
ភយានិតានិញ្ចុំ	ឆន្និតសលោកំ ។

នរអ្នកឯណា	ចិត្តចិន្តាដោយធម្ម
សីលោរក្ខិតំ	រក្សាសីលពុំដែលដាច់ ។
កំហឹងខឹងមានះ	លែងលាកលះបរិបូណ៌ស្រេច
វស្សារៀនសូត្រសេច	ធម៌ពិនិត្យពិនិស្ច័យ ។
ប្រាជ្ញជ្រាបជ្រះជ្រៅ	មិនកំដៅអ្នកដទៃ
វៀរបរទារការនៃ	ត្រេកអរនូវបុត្រភរិយា ។
ឯងឯអស់អំពល់	ពិតពុំផល់ជិតអគ្គិ
អ្នកនោះលោកិយត្រា	នេះទីនេសកិតភ័យខ្លាំង ។

៤៧ — បត្វិ មរុត្វា	ពាណិជ្ជោ មរណារំ
គិត្វា មរសីលំ	ភជា មរសត្តមា ។

លោកថាសត្វបក្សី សោតទោះបីនឹងមរណា
លុះលើមែករុក្ខា ទើបប្រសើរជាបក្សី ។
រីឈ្មួញសោតមរណា លើកេត្រាត្រាច់ដលធី
ភិក្ខុទ្រង់សីលវី- សេសសោតមរក្នុងសីលសង្ឃ ។
ព្រះមហាក្សត្រធិពជ ទ្រង់អំណាចមរណាក្នុង
សង្គ្រាមជ័យទ្រើសទ្រង់ កើតប្រសើរជាក្សត្រា ។

៤៨ — យោធបុគ្គលោ ឧជ្ជនោនោសមា-
ធាយទុក្ខផ្លា- ធិតវស្សកាលេ ។
សុជនោគុណ: សន្តហាយហាវេឡ
ចិរបរិវុត្តោ សប្បុរិសសេដ្ឋា ។
អ្នកកាចកាន់យកទោស ពុំសន្តោសលោកគួរនា
ដូចជ្រុកឈ្មុសយកអា- សោចសីនល្អក់ទុគន្ធ(១) ។
អ្នកសប្បុរស លោកបោលអស់ទាំងទោសំ
ប្រមូលយកគុណំ ដូចហង្សបង់ក្សីរគោក្ខា(២) ។

៤៩ — សសេសសេល- កេឌឆកិរិយា
ញាតិសសេសា សេលកេដេដ្ឋកោ ។
នាអ្នកមួយផ្លាប់មាន ទ្រព្យបើបានបង់ធនោ(៣)

១ មានក្លិនអាក្រក់, ស្អុយ ។ ២ បង់ទឹកទឹកដោះ ។ ៣ បង់ទ្រព្យ ។

ចន្ទសិកាមោ ចិត្តចង់បានដូចដែលវិញ ។
មួយធ្លាប់មានភរិយា ស្និទ្ធស្នេហាដោយស្រឡាញ់
បើស្លាប់ភរិយាមិញ ចង់យកភរិយាទៀតណា ។
អ្នកមួយធ្លាប់មានញាតិ បើឃ្លាឃ្លាតព្រាត់ប្រាសគ្នា
ចិត្តចង់គេអ្នកណា សប្បុរសជាញាតិផង ។
អ្នកមួយធ្លាប់ជាធំ បើថ្លស់អំពីយសផ្គង
រិចិត្តអ្នកនោះហោង នៅធំដូចអតីត(១) ។

៨០ — កាដូកាម្ពុត:- មរក្សមឧកាំ
ឧដូសឆច្ចុំ ភាចាកាម្ពុំសាស្ត្រា ។
លោកថាឈើណាមួល ពុំទាន់ចូលព្រមណា
នោះអ្នកប្រាជ្ញលោកថា ពុំទាន់ហៅជាមួលមាន ។
ក្លូមិណាមួយបើកប ចាំងប្រាសប្រាបទួលទីឋាន
ពុំទាន់ស្ងួនទឹកបាន លោកពុំហៅជាកបឡើយ ។
ឈើត្រង់សោតបើពុំ ទាន់ផ្ដាត់តម្រង់ជាត្រើយ
ពុំទាន់ហៅត្រង់ឡើយ លុះផ្ដាត់ទើបហៅត្រង់ហោង ។
អ្នកណាមួយស្រដី មានបាឡីគាថាផង
លោកឲ្យជឿជាម្ដង កុំសន្និះចិត្តចិន្តា ។

---
១ ដូចពីដើម ។

៥១ — ឥមេ ក៉ាព្យាហិ　　ការេមិចសុកា·
សិតំភិតាជ៉ា　　បញ្ញាសនិដ្ឋិតំ ៗ
ឥមិណាតេដេ·　　ឆបុញ្ញេកុសលំ
យាវនិព្វានំ　　បច្ចយោហោតុមេ ៗ

(ចប់)

# អំពីពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូស៊ីន

របស់លោកដុកទ័រ អង់ទ្រេ-មីកូត៍ (តនិងចប់)

មានមួយផ្លូវទៀត ដែលពុទ្ធសាសនាផ្សាយចូលទៅក្នុងប្រទេសតុងកឹងចាស់ (Le kiaotche) ដោយមានពួកអ្នកដំណើរឬពួកលោកសង្ឃពុទ្ធសាសនាពីឥណ្ឌាបានដើរកាត់ប្រទេសនេះ ដើម្បីចូលទៅប្រកាសសាសនាក្នុងប្រទេសចិន តាំងពីសតវត្សរ៍ដំបូងគ្រិស្តសករាជ ហើយជួនកាលមានលោកសង្ឃជាតិចិនជាច្រើនដែលនាំគ្នាដើរធុតង្គទៅប្រទេសឥណ្ឌា នឹងក្នុងប្រទេសពុទ្ធសាសនា ដែលនៅចន្លោះឥណ្ឌានឹងអូស្ត្រាលីជាដើម ។ ក្នុងរឿងនេះ យើងបានដឹងជាប្រាកដដោយសាររឿងរ៉ាវរបស់លោកធុតង្គ (ជាតិចិន) ឈ្មោះយី-ឈិង ដែលយើងបានពោលរួចមកហើយនោះ នៅខាងចុងសតវត្សរ៍ទី ៧ (ព.ស.៦៤៣) ។ ក្នុងខណៈនេះ ពុទ្ធសាសនារបស់យួនមានមេត្រីយ៉ាងមាំមួននឹងពុទ្ធសាសនារបស់ចិន ។

ក្នុងឆ្នាំ ៩៦៨ (ព.ស.១៥១១) មានរាជវង្សក្សត្រយួន ១ អង្គព្រះនាម ឌិញ-ទៀន-ហ៉ង បានរៀបចំគណៈសង្ឃឲ្យមានជាន់មានថ្នាក់ខ្ពស់ទាប ទ្រង់តាំងលោក ង៉ូ-ចន-លុន ជាអធិបតីគណៈសង្ឃជាន់

នោះ ៗ ក្នុងរាជ្យរបស់ទ្រង់ និងក្នុងរាជ្យក្សត្រជាតំណតមកនៃរាជវង្ស លី ព.ស. ១៥៥៣ ដល់ ១៧៦៣ (១០១០-១២២៥) និងរាជវង្សទ្រឿង ព.ស. ១៧៦៨ ដល់ ១៩៥៦ (១២២៥-១៤១៣) នោះ វត្តអារាម និងគណៈសង្ឃមានសេចក្ដីចំរើនឡើងច្រើននៅក្នុងស្រុក លទ្ធិសាសនាក៏រីកធំឡើង សាយភាយទៅដោយសារប្រជាជនបានគម្ពីរដីកាមកពីប្រទេសចិន ៗ មានល័ក្ខណ៍ជាច្រើនដែលបង្អុលបង្ហាញឲ្យឃើញថាពុទ្ធសាសនាដែលបានទទួលសេចក្ដីសុខក្សេមក្សាន្តដោយសារការទំនុកបំរុងពីពួកក្សត្រដែលមានក្នុងសម័យនោះ អស់វេលា ៥ សតវត្សរ៍ ៗ

តាំងពីខាងចុងសម័យនោះមក មានកំឡាំងរបស់លទ្ធិមួយមកទទឹងទាស់នឹងសេចក្ដីចំរើនរបស់ពុទ្ធសាសនា គឺលទ្ធិកុងហ្វូយស្យាទិស្ដ៍ (ខុង-ជឺ) ដែលជាពួកអ្នកចេះដឹងនិយមហៅថាពួកឡេត្រ ជាអ្នកទទួលកាន់ប្រតិបត្តិតាម ហើយអំណាចរបស់លទ្ធិនេះផ្ដើមកើតឡើងយ៉ាងពិតប្រាកដនោះ ក្នុងសម័យរាជវង្ស មីង ក្សត្រជាតិចិន ៗ កេរ្ដិ៍ឈ្មោះសេចក្ដីគោរពកោតក្រែងពួកឡេត្រនេះតាំងពីសតវត្សរ៍ទី ១៦ (ព.ស ២០៤៣ ដែលពួកក្សត្រលែងជួយទំនុកបំរុងពុទ្ធសាសនាដោយពេញទីតទៅ បែរជាជួយកំឡាំងដល់ពួកអ្នកមានទ្រព្យសម្បត្តិនិងពួកអ្នកមានសតិបញ្ញាខាងលទ្ធិសាសនារបស់ខុងជឺ ឬលទ្ធិតៅអ៊ីស្ដ៍វិញ ៗ

# ព្រះពុទ្ធសាសនារបស់យួនក្នុងសម័យបច្ចុប្បន្ននេះ តើមានអាការដូចម្ដេច

ត្រូវតែទទួលដឹងថា ប្រជាជនជាតិយួនជាចំនួនច្រើនដែលប្រកាន់ថាខ្លួនជាអ្នកកាន់ពុទ្ធសាសនានោះ ពួកនេះឥតមានគំនិតគិតគូរខាងលទ្ធិរបស់ព្រះពុទ្ធសោះឡើយ រៀរលែងតែលទ្ធិនេះទៅប្រតិស្ឋានទៅទីដទៃ ៗ សូម្បីការសាសនារបស់ពួកឧបាសកឧបាសិកានឹងពួកលោកសង្ឃពុទ្ធ-សាសនា ១ ចំណែកសឹងមានចំនួនច្រើន ដែលទទួលខ្លួនជាអ្នកកាន់ព្រះពុទ្ធសាសនានោះក៏ដោយ ក៏នៅតែឃើញជាសាសនាដែលពួកយួនយល់មិនបាន ដោយឧបាយកលរបស់ពួកចិននឹងពួកទីបេត៍ធ្វើមិនឲ្យយល់បានដោយត្រឹមត្រូវ គឺមិនយល់សេចក្ដីជាខ្លឹមសាររបស់សាសនាដូចម្ដេចឡើយ ៗ ប្រវេណីសាសនាដែលគេត្រូវគោរពជាដំបូងទុកជាសរណៈនោះមាន ៣ យ៉ាងគឺ អា-ឌិ-ដា (ព្រះអមិតាភៈ) ឆិច-កា-មោ-នី (ព្រះពុទ្ធ) នឹង រី-អា (ព្រះមៃត្រេយ) ៗ នៅក្បែរខាងព្រះទាំង ៣ អង្គនេះមានព្រះ ក្វាង-អឹម (អវលោកិតេស្វរៈ) មានព្រះហស្ត ១០០០ គង់នៅនឹងព្រះមៃត្រេយមានពោះធំ ទ្រង់ញញឹមប៉ប្រែ ជារូបបែបភាពចិន ដែលចិននាំចូលមកផ្សាយ មានរូបសាវកពីរអង្គតែងមានជារឿយ ៗ ដែរ គឺឈ្មោះ វុង-ឌូ (មញ្ជុស្រី) នឹង កោ-ហៀង (ព្រះសមន្តភទ្រ)

លោកអគ្គទី១ជិះសិង្ហ អគ្គទី២ជិះដំរី បន្ទាប់តទៅទៀតទេវតា ក្វាង-ឡុង និងទេវធីតា ក្វាង-យិន ។

ប៉ុន្តែនៅជ្រុងម្ខាងដែលមានពួកទេវតាពុទ្ធសាសនាគង់នៅជិតៗគ្នា ហើយនៅជួរខាងមុខបង្អស់នោះមានពួកទេវតា តាអ៊ែស៊ី គឺ ឡាវ-ក្វាង (តៅ-ស៊ី) យូ-ហ្វាង ជាអ្នកកាន់សប្តុបរិសុទ្ធ ជុំកា-ហ្វាង ជាចក្រពត្តិខាងថ្មកែវ និងមានសេនាបតីពីរនាក់ គឺ ចាក់-ជាវ និងឈាំ-តាវ បើមិនបាច់រាប់តាមយសសក្តិអ្នកតាអស់នោះ គឺ អុង-តាវ ជាអ្នកតារក្សាផ្ទះ និង អុង-យូ-ពេប ជាអ្នកតារក្សាដើមក្រាន ។ នៅប្រទេសគុងកង មានប្រពៃណីកាន់សាសនាតែលោក (តាំ-កួ) ឬ ជួ-យី មានពួកទេវតាស្រីជាចំនួនច្រើន ។

ឯលទ្ធិទី៣ជាលទ្ធិរបស់ខុងជឺ ខាងពួកខ្សេត្រ ដែលរាជការទទួលរាប់លទ្ធិនេះទុកជារបៀបសាសនាដែលពិតប្រាកដរបស់រាជការ និងលទ្ធិការប្រកាន់អារក្សអ្នកតាតាមថ្នាក់តូច-ធំទាំងពួង ។

កន្លងទីបំផុត គេបានបន្ថែមលទ្ធិគោរពជីដូនជីតាជាបុព្វបុរសក្នុងលទ្ធិទាំង ៣ នេះ១ទៀតដែលជាលទ្ធិជ្រួតជ្រាបចូលទៅក្នុងចិត្តប្រជាជនយ៉ាងច្រើនបំផុត ហើយមានការគោរពដល់ខ្មោចបិសាច ដល់អ្នកតារក្សាស្រុក អ្នកតារក្សាភ្នំ អ្នកតារក្សាទ្រព្យសម្បត្តិ ដើមឈើសក្តិសិទ្ធ (ដើមពោធិ៍) ដុំថ្ម និងមន្តអាគមគាថាផ្សេងៗទៀតជាអនេកប្រការ ។

ការដែលសាសនាប្រឡូកប្រឡំគ្នានេះ តែងតែមានធម៌ក្នុងលទ្ធិនោះៗ ជាទំនាស់ទីងគ្នាជានិច្ច ក៏នៅតែមិនបំបែកចិត្តគំនិតរបស់ជាតិយួនឲ្យបែកចេញទៅឡើយ គ្រាន់តែជាទំនាស់ទីងបែបផែនដែលមានក្នុងចិត្តគំនិតយួនដែលស្ងប់រៀបរយ ជាទំនាស់ទីងសេចក្តីមិនទៀងទាត់ជាប់ស្រេច ជាទំ-នាស់ទីងការមិនដឹងជាទីងពេសការខាងណា ធ្វើឲ្យចិត្តកន្ទុះក ជាទំនាស់ការមិនស្គាល់សេជាតិធម៌អភិធម្ម ជាទំនាស់ទីងការគួរខ្ពើមចំពោះលទ្ធិវិធីគ្រប់យ៉ាង ដែលនាំឲ្យបានសេចក្តីលំបាកទីងឥតប្រយោជន៍ ។ ប៉ុន្តែបែរជាលទ្ធិប្រពៃណីអស់នេះនៅរួបរួមជាមួយគ្នាស្រសបួលក្នុងចិត្តគំនិតរបស់យួនទីងជាប់ជាជំណាតគ្នារៀងៗមកដោយងាយស្រួល ហើយប្រព្រឹត្តទៅតាមសេចក្តីត្រេការនៃវិញ្ញាណក្ខន្ធរបស់ខ្លួនដែលជារបស់ប្រចាំត្រកូល ឬប្រចាំនៅទីងកិច្ចសព្វសារពើ ។

ការដែលលទ្ធិសាសនាប្រឡូកប្រឡំរកែនេះហើយទើបកើតមានលទ្ធិកោដាយយ៉ាងច្បាស់ទែងឡើង ចាត់ជាការបង្កើតព្រះអង្គទី ៣ ឡើងក្នុងបូញាប្រទេសក្នុងឆ្នាំ ១៩២៦ ( ព.ស. ២៤៦៩ ) ក្នុងវត្តតៃនិញ ក្នុងវិហារដែលដំកល់គ្រឿងសក្ការបូជាមានទាំងលទ្ធិសាសនាខុងជឺ លទ្ធិអារក្សអ្នកតា លទ្ធិសាសនាគ្រិស្ត លទ្ធិតាវអ៊ីស្ត ទីងពុទ្ធសាសនា ជាទីប្រជុំរួមលទ្ធិសាសនានានាជាច្រើនដូចបញ្ចេញឈ្មោះមកនេះ ។

កាលពី ២-៣ ឆ្នាំមកហើយនោះ មានការប្រែប្រួល ១ កើតឡើង ដើម្បីទំនុកបម្រុងព្រះពុទ្ធសាសនាក្នុងប្រទេសកូសាំងស៊ីនទីងអណ្ដាម នៅក្រោមឥទ្ធិពលនៃពុទ្ធសមាគម ដែលបានតាក់តាំងឡើងនៅក្រុងហ្សៃទីងព្រៃនគរ ។ មានលោកសង្ឃយួន ១ ក្រុមដែលមានចំណេះចេះដឹងច្រើន បានចេញផ្សាយលទ្ធិបរិសុទ្ធត្រឹមត្រូវមួយក្នុងពួកគណៈសង្ឃទីងក្នុងវៀយក្មេងណាស់ ហើយបានផ្សាយចេញទៅក្នុងស្រុកបានតិចពេកផ្ទៃមាត់ទន្លេមេគង្គពីព្រែកជ្រៅ ហើយមិនចាំយូរប៉ុន្មានទៀត ។ ឯស្រុកខ្មែរ-ក្រោម ...ផងស្រុកតំណៀង ពុទ្ធសាសនិកជនជាច្រើនក៏នាំគ្នាជួយឧបត្ថម្ភសេចក្ដីប្រែប្រួលខាងផ្លូវសាសនាតាមទំនងនេះ ដោយយកចិត្តទុកដាក់ណាស់ (ដូចមើលឃើញសព្វថ្ងៃនេះ) ។

ព្រៃនគរ ណូវែមប្រ៍ ១៩៣៩

ដុកទ័រ អង់ដ្រេ-មីក្វត៍

(តមក)

## វគ្គទី ៤

# អំពីការទ្រុឌទ្រោមនៃក្រុងអាថែន

ការដែលស្រុកអាថែនមានជ័យជំនះសង្គ្រាមដែលកន្លងមកហើយក្តី ការដែលស្រុកអាថែនកសាងឡើងយ៉ាងរហ័សរួសរាន់ក្រោយសង្គ្រាមនោះក្តី ធ្វើឲ្យស្រុកអាថែនចំរើនរុងរឿងឡើងនិងមានអំណាចមាំមួនជាឯកកងចំណោមស្រុកក្រិកដូចគ្នា ប្រទេសក្រិកជិតខាង ដូចជាថែប៍និងកូរិន្ធ ក៏នឹកព្រួយខ្លាចអាថែនរំលោភមកលើខ្លួន ទើបនាំគ្នាទៅរួបរួមជាមេត្រីនឹងស្ប៉ាត ដើម្បីរាំងរាមិនឲ្យអាថែនផ្សាយអំណាចចូលមកបាន ។ តាមទំនងនេះឃើញថាប្រទេសបែកខ្ញែកចេញជា ២ ពួក គឺក្រិក ១ ពួក នៅខាងប៉េលោប៉ូណែសនិងក្រិកកណ្តាល មានស្រុកស្ប៉ាតជាប្រមុខ ក្រិក ១ ពួក គឺពួកដែលនៅតាមឆ្នេរសមុទ្រនិងតាមកោះក្នុងសមុទ្រអេសេ មានស្រុកអាថែនជាប្រមុខ ទាំងពីរពួកនេះមានហេតុដែលនាំឲ្យឈ្លោះទាស់ទែងប្រណាំងប្រជែងគ្នាមាន ៣ ប្រការគឺ ការប្រណាំងប្រជែងដណ្តើមយកផលប្រយោជន៍ប្រការ ១ ការប្រណាំងប្រជែងដណ្តើមយកជាតិក្រិកដែលមានសែស្រឡាយតមកពីពួក ដូរីយាង់ និងពួកក្រិក

ដែលមានសៃស្រឡាយតមកពីពួក អ៊ីអូនីយ៉ាង់ ប្រការ ២ ការប្រណាំងប្រជែងគ្នារវាងការត្រួតត្រាស្រុកដោយអំណាចមន្ត្រី និងអំណាចប្រជារាស្ត្រប្រការ ១ ហេតុទាំង ៣ ប្រការនេះជាជួនទាស់ទែងគ្នាយ៉ាងធំ ។

តាំងអំពីខាងចុងបង្ហើយសង្គ្រាមនោះតមកជាវេលា ១៨ ឆ្នាំ ក៏កើតសង្គ្រាមរវាងពួកក្រិកផងគ្នាឡើង ហេតុដែលនាំឲ្យសង្គ្រាមកើតឡើងនេះ ដោយហេតុអាថែនទ្យទៅញុះញង់ស្រុកករស៊ីរ៍ ដែលជាចំណុះរបស់ស្រុកកូរិនថ៍នោះឲ្យបង្កការចលាចលឡើង កូរិនថ៍ជាបក្ខពួករបស់ស្ប៉ាត ហើយស្រុកទាំងពីរនេះទើបក្លាយទៅជាខ្សែជួនសង្គ្រាមឡើង ហៅថា "សង្គ្រាមប៉េឡោប៉ូណែស" ច្បាំងគ្នាអស់វេលា ២៧ ឆ្នាំ គឺចាប់ផ្ដើមតាំងអំពី ព.ស. ១១២ ដល់ ព.ស. ១៣៩ (មុន គ.ស. ៤៣១-៤០៤) ។

អំពីចម្បាំងប៉េឡោប៉ូណែស — សង្គ្រាមគ្រានេះអាចបែងចែកជា ៣ ភាគ គឺ ភាគទី ១ ពួកស្ប៉ាតចាប់ផ្ដើមលុកលុយពួកអាថែនទ្យចូលមកតាមផ្លូវជើងគោកតាមអាណាចក្រអ័ទិក ។ ចំណែកខាងពួកអាថែនទ្យគ្រាន់តែលើកទ័ពទៅតទល់នឹងពួកស្ប៉ាតតាមផ្លូវជើងគោក បែរលើកទ័ពជើងទឹកទៅវាយតាមមាត់សមុទ្រប៉េឡោប៉ូណែសទៅវិញ ទុកបណ្ដោយឲ្យសង្គ្រាមជើងគោកធ្វើការទៅតាមយថាកម្ម នេះជាគ្រោងការណ៍ចម្បាំងរបស់ពេរីក្លេសដែលត្រូវការឲ្យពួកអាថែនទ្យជាម្ចាស់សមុទ្រយ៉ាងខ្ជាប់ខ្ជួន ។

លុះពួកកងទ័ពស្ប៉ាតកាន់តែរុកកាន់ទន្ទ្រានចូលមក បណ្ដាប្រជាជនអ្នកស្រុកក្រៅក៏នាំគ្នារត់មូលមកចូលក្រុងពេញទាំងស្រុកអាថែន បណ្ដាលឲ្យកើតកាលរោគ (ប៉្លេស្ដ៍) ឡើងក្នុងជំនុំពួកនេះមុន ហើយក៏រាលចូលទៅពាសពេញ បានប្រហារជីវិតប្រជាជនអស់ជាច្រើន ហើយខ្លួនបេរីក្លេសដែលជាមេដឹកនាំធំរបស់អាថែនក៏ក្ស័យជីវិតបង់ដោយកាលរោគគ្រានេះ (ព. ស. ១១៤ មុន គ. ស. ៤២៩) ។ លុះបេរីក្លេសអនិច្ចកម្មទៅហើយ ពស៊ែក៏រើសយក ក្លេអុង ជាធាយករបស់អាថែនជំនួស បុរសដេម៉ាកោ ដែលជាមេអ្នកជួញស្បែកសត្វ ។ ខ្លួនបានយកពលចាប់ពួកទាហានស្ប៉ាតបានចំនួន ៣០០ នាក់តាមមាត់សមុទ្រទិសខាងលិចរបស់ប៉េឡូប៉ូណែស ។ ចំណែកខាងពួកស្ប៉ាតក៏ព្យាយាមប្រឹងកាត់ស្បៀងរបស់ស្រុកអាថែន ទើបចូលវាយចូលទៅស្រុកត្រាសដែលជាស្រុកធ្វើស្រូវសាលីជាស្រុកដ៏ជ្រកស្រូវរបស់អាថែន ។ មេទ័ពរបស់ស្ប៉ាតម្នាក់ឈ្មោះប្រាជ់ស៊ីដាស វាយបានស្រុកអ័មហ្វីប៉ូលិស ជាខេត្តរបស់ស្រុកត្រាសនោះបាន ទើប ក្លេអុង មេទ័ពអាថែនលើកទ័ពទៅច្បាំងដោយខ្លួនឯង ដើម្បីដណ្ដើមស្រុកនេះយកមកវិញ តែក្នុងទីបំផុត មេទ័ពទាំងពីរគឺ ប្រាជ់ស៊ីដាស នឹង ក្លេអុង ក៏អនិច្ចកម្មទៅទាំងពីរនាក់ ។

(មានត)